វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ: ០៣៦ប្រក/ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០០៣

## ប្រកាសអន្តរក្រសួងស្តីពីការសំរួលសមាសភាពសមាជិកគណៈកម្មការសុរិយោដី ក្រុងភ្នំពេញ និង ខេត្តកំពង់ឆ្នាំង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងរៀបចំដែនដី នគូរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី
- យោងប្រកាសអន្តរក្រសួងខេត្ត ០៧៦ប្រក.ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០២ របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងប្រកាសលេខ ១៩៤ប្រក/បុ ចុះថ្ងៃទី០៧ ខែវិច្ឆការ ឆ្នាំ២០០២ និងលេខ១៨៣ប្រក/បុ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០០២ របស់ ក្រសួងរៀបចំ នគរូនីយកម្ម និងសំណង់
- តាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

Downloaded from http://www.khmerlaws.com

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

**សំរេច**

ប្រការ ១ :

ត្រូវបានសំរួលសមាសភាពសមាជិកគណៈកម្មការសុរិយោដីក្រុងភ្នំពេញ និង ខេត្តកំពង់ឆ្នាំង ដោយតែងតាំង :

១- លោក ឈួន សុធី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក្រុងភ្នំពេញជាសមាជិកគណៈកម្មការ សុរិយោដី ក្រុងភ្នំពេញជំនួស លោក ស៊ិន សុខ ដែលត្រូវបានទទួលភារកិច្ចថ្មី

២- លោក កែវ សឿងសោភ័ណ្ឌ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តកំពង់ឆ្នាំងជាសមាជិកគណៈកម្មការ សុរិយោដី ខេត្តកំពង់ឆ្នាំង ជំនួសលោក តុក ហុងលី ដែលត្រូវបានទទួលភារកិច្ចថ្មី

ប្រការ ២:

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ នាយកខុទ្ទកាល័យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អភិបាលរាជធានីភ្នំពេញ និងខេត្តកំពង់ឆ្នាំង លោក ឈួន សុធី និង លោក កែវ សឿងសោភ័ណ្ឌ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com